# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតី
# ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល ការងាររយៈពេល ០២ ខែ និងទិសដៅអនុវត្តបន្ត
# របស់ក្រុមការងារថ្នាក់ជាតិមូលដ្ឋានខេត្តកំពត




ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត នាព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ បានអញ្ជើញជាអធិបតី ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររយៈពេល ០២ ខែ និងទិសដៅអនុវត្តបន្ត របស់ក្រុមការងារថ្នាក់ជាតិ ខេត្ត ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅសាលប្រជុំសាលាខេត្តកំពត ។




តាមរបាយការណ៍ របស់លោកស្រី យូ សុគន្ធ អភិបាលរង តំណាងលោក ចាន់ ចេស្តា អភិបាល នៃគណៈអភិបាលខេត្តកំពត បានបញ្ជាក់ថាៈ ក្រុមការងារចុះមូលដ្ឋានខេត្ត ក្រុង ស្រុក បានចុះធ្វើវេទិកាសាធារណៈ ក្នុងខែមករា និងខែកុម្ភៈ បានចំនួន១៥ លើក មានសមាសភាពចូលរួមពីក្រុមការងារថ្នាក់ជាតិ ខេត្ត ក្រុង ស្រុក ចំនួន ៥១២ នាក់ ស្រី ១២ នាក់ និងប្រជាពលចូលរួមចំនួន ២០៩១ នាក់ ស្រី ៩៩២ នាក់ ។ បញ្ហាសំណូមពរមានចំនួន ៨៤ ករណី បានដោះស្រាយបានចំនួន៥២ ករណី កំពុងដោះស្រាយចំនួន២៧ ករណី និងមិនទាន់ដោះស្រាយបានចំនួន ០៥ ករណី ។




ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានវាយតម្លៃខ្ពស់ និងកោតសរសើរដល់ក្រុមការងារថ្នាក់ជាតិគ្រប់លំដាប់ថ្នាក់ដែលបានខិតខំចុះធ្វើវេទិកាសាធារណៈ ដើម្បីដោះស្រាយសំណូមពរ របស់ប្រជាពលរដ្ឋដែលធ្វើឲ្យបញ្ហាត្រូវបានដោះស្រាយ ជាបន្តបន្ទាប់ ហើយរាល់វេទិកានីមួយៗ បញ្ហាសំណូមពរត្រូវបានកាត់បន្ថយកាន់តែតិចទៅៗ។ ឆ្លៀតឱកាស នោះ លោកទេសរដ្ឋមន្ត្រី បានណែនាំថា រាល់វេទិកាសាធារណៈ និងវេទិកាផ្សេងៗ សូមក្រុមការងារ ធ្វើការផ្សព្វផ្សាយឲ្យបានផុលផុស ពីសាររបស់ប្រមុខរដ្ឋាភិបាល សម្តេចតេជោ ហ៊ុន សែន ដែលបានបញ្ជាក់ថាៈគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុទាំងអស់នៅកម្ពុជា ជារបស់ឯកជនពុំមែនជារបស់រដ្ឋឡើយ។ ជាមួយគ្នានេះ បញ្ហាគ្រឿងញៀនក៏ជាយុទ្ធនាការ របស់រាជរដ្ឋាភិបាលដែរ ដែលឯកឧត្តមស្នើឲ្យមានការផ្សព្វផ្សាយឲ្យបានទូលំទូលាយពីផលប៉ះពាល់របស់វា ។



ស្ថិតក្នុងឱកាសនោះ លោកទេសរដ្ឋមន្ត្រី ក៏បានលើកឡើងពីគោលនយោបាយ របស់រាជរដ្ឋាភិបាល ស្តីពីបញ្ហាទឹកភ្លើង ដែលប្រជាពលរដ្ឋ តែងលើកឡើងទាក់ទង នឹងការផ្គត់ផ្គង់ និងតម្លៃប្រើប្រាស់ ដោយលោកបានបញ្ជាក់ថា តាមគោលដៅ នៅឆ្នាំ២០១៨ ខាងមុខ អគ្គិសនីរបស់រដ្ឋនឹងតឲ្យដល់ភូមិទូទាំងប្រទេស ឯទឹកស្អាត ឆ្នាំ២០១៨ នឹងតបណ្តាញដល់ផ្ទះ ប្រជាពលរដ្ឋជាង៩០% នៅតាមទីប្រជុំជន ។

ដោយឡែក នៅខេត្តកំពត ឯកឧត្តមទេសរដ្ឋមន្ត្រី បានជម្រាបជូន ពីគម្រោងដ៏ធំរបស់ក្រសួង និងក្រុមហ៊ុនចិន ក្នុងការយកទឹកពីវារីអគ្គិសនី ភ្នំកំចាយខេត្តកំពត មកផលិតផ្គត់ផ្គង់មានវិសាលភាព គ្របដណ្តប់ចំនួនពីរខេត្ត គឺខេត្តកំពត និងខេត្តកែប ដែលបច្ចុប្បន្នក្រុមហ៊ុន ជំនាញចិនកំពុងសិក្សា ពីសមិទ្ធិលទ្ធភាព។



ទាក់ទង នឹងការតវ៉ា ដោយមានការញុះញង់ឲមានការតម្លើងថ្លៃទឹក នៅពេលថ្លៃភ្លើងចុះថោក ឬតម្លៃទឹកហេតុអ្វីក៏ខុសគ្នាពីតំបន់មួយទៅតំបន់មួយ រឺពីខេត្តមួយទៅខេត្តមួយ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធបានធ្វើការពន្យល់ថាៈ ទោះបីថ្លៃភ្លើងចុះ ក៏ថ្លៃទឹកមិនអាចចុះគំហុកដូចភ្លើងបានដែរ ហើយបើរោងចក្រផលិតទឹកស្អាតនោះ មិនទាន់មានភ្លើងរដ្ឋដល់ទៀតគឺកាន់តែពិបាកចុះហើយ ។ ហេតុអ្វី ? ពីព្រោះបច្ចុប្បន្ននេះក្រសួងមុនឲ្យវិស័យឯកជនទទួល សិទ្ធិធ្វើអាជីវកម្មទឹកស្អាត ក្រសួងគិតគូរួចរាល់ហើយ តាមរយៈការសិក្សាពីសមិទ្ធិលទ្ធភាព និងគណនាថ្លៃដើមឲ្យបានច្បាស់លាស់ ពីព្រោះក្រសួងអនុញ្ញាតិ ឲ្យប្រតិបត្តិករទឹកស្អាតឯកជនទទួលបាន ប្រាក់ចំណេញ ដុលត្រឹម១០% ប៉ុណ្ណោះ នៃការចំណាយថ្លៃដើមរបស់ខ្លួន។

បើទាមទារចុះថ្លៃគំហុក ច្បាស់ណាស់ប្រតិបត្តិករទឹកឯកជន នឹងក្ស័យធន ហើយបើទឹកត្រូវផ្តាច់តែរយៈពេលពីរទៅបីថ្ងៃ តើប្រជាពលរដ្ឋទ្រាំបានទេ? ពេលនោះ តើគាត់ចំណាយលុយពី ១៥០០៛ ទៅ ២៥០០៛ អាចទិញទឹកអម្រែកបានមួយម៉ែត្រគូប ស្មើនិង១ពាន់លីត្របានទេ? នៅពេលដែលថ្លៃទឹកខាងលើមានការតបណ្តាញដល់ផ្ទះ និងអាចត្រងផឹកបាន ដោយមិនខ្លាចមានរោគឆ្លង។ ចំពោះថ្លៃទឹកខុសគ្នា លោកទេសរដ្ឋមន្ត្រីធ្វើ ការពន្យល់ថាៈ ថ្លៃទឹកខុសគ្នាពីតំបន់មួយ រឺពីខេត្តមួយ គឺដោយសារមូលហេតុ

ច្រើនយ៉ាងដូចជាៈ ប្រភពទឹកខុសគ្នា ទឹកមានមេរោគដែលត្រូវចំណាយវត្ថុធាតុកំចាត់ច្រើន រឺតិច អគ្គិសនីថ្លៃខុសគ្នា និងដង់ស៊ីតេរស់នៅរបស់ប្រជាជនខុសគ្នាជាដើម។ល។ ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី បានកោតសរសើរដល់អាជ្ញាធរខេត្តកំពត ដែលបានទប់ស្កាត់បានទាន់ពេលវេលា នូវភាពអនាធិបតេយ្យចាប់ដីរដ្ឋ រឺដីឯកជន ធ្វើកម្មសិទ្ធិ ដែលកើតឡើងនៅភូមិតេជោអភិវឌ្ឍន៍កន្លងទៅថ្មីៗនេះ ហើយមាននិន្នាការទៅបណ្តាខេត្ត មួយចំនួនទៀត ដោយមានអ្នកនយោបាយនៅពីក្រោយខ្នង ក្នុងន័យបង្កភាពអាប់អួរ មុនការបោះឆ្នោតខាងមុខ ។

ជាចុងក្រោយ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានណែនាំ ដល់សមាជិកក្រុមការងារទាំងអស់ ទោះ មិនមានវេទិការសាធារណៈ ក៏ត្រូវតែនៅរក្សាការចុះជាប់ជាមួយប្រជាពលរដ្ឋ ដើម្បីដឹងពីសុខទុក្ខរបស់ពួកគាត់ នៅមូលដ្ឋានពិតប្រាកដ ជាពិសេស គឺផ្សព្វផ្សាយ នូវគោលនយោបាយ កែទម្រង់ និងអនុគ្រោះរបស់រាជរដ្ឋាភិបាល ដើម្បីសម្រួលបន្ទុកជីវភាពរបស់ប្រជាពលរដ្ឋលើ ការបញ្ឈប់និងលើកលែង លើតម្លៃសេវាផ្សេងៗ មានដូចជាៈ ការបញ្ឈប់ការយកពន្ធលើមធ្យោបាយ ប្រចាំឆ្នាំ ( ម៉ូតូ) ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ អចលនទ្រព្យដល់អ្នក ជាប់សាច់ញាតិបង្កើត ការបញ្ចុះថ្លៃអគ្គិសនី ការតបណ្តាញទឹកស្អាតក្នុងតម្លៃថោកដល់ផ្ទះជួលរបស់កម្មករ ការបញ្ឈប់យកភាសុ ីការលក់ល្អី កញ្ច្រែងតាមផ្សារ ការបញ្ឈប់ការយកកម្រៃ សេវាអត្រានុកូលដ្ឋាន អត្តសញ្ញាណប័ណ្ណ សៀវភៅ គ្រួសារ សៀវភៅស្នាក់នៅ ការបំបាត់ការដាក់កុងត្រូល ស្នាក់យកលុយខុសច្បាប់ ការតម្លើងប្រាក់បៀវត្សន៍ជូនមន្ត្រីរាជ ការ និងតម្លើងប្រាក់ឈ្នួលដល់កម្មករ ។ល។

